# តើត្រូវទៅកាន់ទីណានៅគ្រាឥឡូវនេះ? ការណែនាំឆ្ពោះទៅកាន់VCE និង VCAL

ព័ត៌មានសំរាប់សិស្ស
ដែលអង់គ្លេសគឺជាភាសាទីពីរ
និងមាតាបិតារបស់សិស្សទាំងនោះ

State Government Victoria
Department of Education & Training

VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

© 2006

## អំពី VCE

### តើ VCE គឺជាអ្វី?

វិញ្ញាបនបត្រអប់រំនៃរដ្ឋវិកតូរីយ៉ា (Victorian Certificate of Education [VCE]) គឺជាវិញ្ញាបនបត្រដែលទទួលស្គាល់ការបំពេញការសិក្សាមធ្យមសិក្សារបស់អ្នកដោយជោគជ័យ។ វាជាលក្ខណៈសម្បត្តិថ្លៃថ្លាមួយដែលត្រូវបានគេទទួលស្គាល់ក្នុងពិភពលោក។ VCE ផ្តល់ផ្លូវដើរសំរាប់ការសិក្សាតទៅទៀតនៅសាកលវិទ្យាល័យ ការសិក្សាបច្ចេកវិជ្ជានិងការសិក្សាបន្ថែមទៀត (TAFE) និងឆ្ពោះទៅកាន់មជ្ឈដ្ឋានប្រកបការងារ។ អ្នកថែមទាំងមានលទ្ធភាពសិក្សារៀនសូត្រធ្វើកូនជាង ឬបណ្តុះបណ្តាលធ្វើការនៅតាមសាលារៀន ក្នុងវង្វង់ VCE របស់អ្នកផងដែរ។

### ពេលណាទៅដែលខ្ញុំអាចចាប់ផ្តើម VCE របស់ខ្ញុំ?

គេរៀបចំ VCE ដើម្បីឲ្យសិស្សសិក្សានៅថ្នាក់ទី 11 និងទី 12 ប៉ុន្តែសិស្សអាចចាប់ផ្តើមនៅថ្នាក់ទី 10 ។ សិស្សថ្នាក់ទី 10 ប្រហែលពាក់កណ្តាលនៅក្នុងរដ្ឋវិកតូរីយ៉ា សិក្សា unit (ផ្នែក)ខ្លះនៃ VCE ។

### តើកម្មវិធី VCE គឺជាអ្វីទៅ?

កម្មវិធី VCE មួយ គឺជាកម្មវិធីសិក្សាទាំងមូលនៃមុខវិជ្ជាសិក្សាដែលអ្នកនឹងត្រូវសិក្សាដើម្បីបំពេញសព្វគ្រប់នូវ VCE របស់អ្នក។ អ្នកអាចជ្រើសរើសយកចេញពីមុខវិជ្ជាធំទូលាយនៃ VCE ។

### តើខ្ញុំត្រូវរើសយកចេញពីអ្វីទៅ?

មានមុខវិជ្ជាជាង 90 នៅក្នុង VCE សំរាប់ឲ្យអ្នកជ្រើសរើស។ អ្នកអាចរកឃើញបញ្ជីនៃមុខវិជ្ជាទាំងអស់នេះនៅក្នុងទំព័រទី 3 និងទី 5 ។ ក្នុងចំណោមមុខវិជ្ជាទាំងអស់នេះ មុខវិជ្ជាជាង 30 គឺជាកម្មវិធីអប់រំនិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VCE Vocational Education and Training [VET]) ដែលផ្តល់លក្ខណៈសម្បត្តិឧស្សាហកម្មទទួលស្គាល់ទូទាំងប្រទេសផងដែរ។ អ្នកមានជំរើសផ្សេងៗផងដែរ ឧទាហរណ៍: នៅក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រ អ្នកអាចសិក្សាអំពីបដិវត្តន៍ ប្រទេសអ៊ីតាលីសម័យកាល Renaissance ឬ ប្រវត្តិសាស្ត្រនៃប្រទេសអូស្ត្រាលី។ អ្នកក៏អាចជ្រើសយកចេញពីមុខវិជ្ជាគណិតសាស្ត្រមួយចំនួន ឬក្រុមសិក្សា ឬការសំដែងតន្ត្រីទោលផងដែរ។ ក៏មានមុខវិជ្ជាភាសា 46 ក្រៅពីអង់គ្លេស (LOTE) ដែរ។

ជាទូទៅ មុខវិជ្ជាមួយនៃ VCE ត្រូវបានគេរៀបចំឲ្យមានរយៈពេលមួយឆ្នាំ ហើយរួមមាន unit (ផ្នែក) មួយចំនួន។ unit មួយមានរយៈពេលកន្លះឆ្នាំ ឬមួយឆមាស។ សិស្សអាចសិក្សា unit ទី 1 និងទី 2 ជា unit តែមួយ - ពោលគឺ គ្រាន់តែ unit ទី 1 ឬគ្រាន់តែ unit ទី 2 - ប៉ុន្តែត្រូវសិក្សា unit ទី 3 និងទី 4 តាមលំដាប់របស់ unit ទាំងពីរ។ បើអ្នកចុះឈ្មោះរៀន unit ទី 3 នៅក្នុងមុខវិជ្ជាមួយ គេក៏រំពឹងថា អ្នកនឹងចុះឈ្មោះរៀន unit ទី 4 នៃមុខវិជ្ជានោះដែរ ដែលជាធម្មតាគឺនៅក្នុងឆ្នាំ ដដែល។

ជាទូទៅ កម្មវិធី VCE មួយមាន unit ចំនួនពី 20 ទៅ 24 ដែលត្រូវសិក្សានៅពេលពីរឆ្នាំ យ៉ាងណាមិញ អ្នកអាចផ្លាស់ប្តូរចំនួន unit ដែលអ្នកសិក្សាក្នុងពេលមួយឆ្នាំៗ។

ជាធម្មតា unit ទី 3 និងទី 4 ត្រូវបានសិក្សានៅក្នុងឆ្នាំបញ្ចប់របស់អ្នកនៅសាលារៀន។ បើអ្នកគ្រោងសិក្សា unit ទី 3 និងទី 4 នៅក្នុងថ្នាក់ទី 11 សូមចងចាំថា unit ទាំងនេះលំបាកជាង unit ទី1 និងទី 2 ។

នៅពេលធ្វើការជ្រើសរើសរបស់អ្នក អ្នកគួរពិចារណានូវមុខវិជ្ជាដែល:

- អ្នកចាប់អារម្មណ៍
- អ្នកពូកែ
- នាំឆ្ពោះទៅកាន់ការងារដែលអ្នកចង់ធ្វើ
- រៀបចំអ្នកសំរាប់វគ្គបណ្តុះបណ្តាល ឬវគ្គឧត្តមសិក្សាដែលអ្នកកំពុងពិចារណា
- ផ្តល់ការទទួលស្គាល់ VET ពោលគឺកម្មវិធី VCE VET មួយដែលនាំឆ្ពោះទៅកាន់ការទទួលលក្ខណៈសម្បត្តិ VET មួយ ក្នុងវង្វង់ VCE របស់អ្នក។

**តើខ្ញុំអាចជ្រើសយកអ្វីទៅនៅឯសាលារៀនខ្ញុំ?**

សាលារៀននីមួយៗសំរេចនូវអ្វីទៅដែលជាបណ្តាមុខវិជ្ជា VCE និងកម្មវិធី VCE VET ដែលសាលារៀននឹងផ្តល់ឲ្យ ហើយ និងតារាងពេលវេលាសំរាប់ផ្តល់មុខវិជ្ជានិងកម្មវិធីទាំងនោះ។

អ្នកក៏អាចសិក្សានៅក្រៅសាលារៀនអ្នកផងដែរ (ឧទាហរណ៍: តាមរយៈសាលាភាសានៃរដ្ឋវិកតូរីយ៉ា [Victorian School of Languages]) បើសាលារៀនអ្នកមិនអាចផ្តល់មុខវិជ្ជាជាក់លាក់ដែលអ្នកចាប់អារម្មណ៍ចង់សិក្សាទេនោះ។

អ្នកគួរឆែកសាកសួរមិនត្រឹមតែអំពីមុខវិជ្ជា VCE ទាំងពួងដែលសាលារៀនអ្នកផ្តល់ឲ្យប៉ុណ្ណោះទេ គឺថែមទាំងថាតើមុខវិជ្ជាទាំងឡាយដែលអ្នកជ្រើសយក សមស្របតាមតារាងពេលវេលារបស់សាលារៀនអ្នកដែរឬទេ។

**តើខ្ញុំមានសិទ្ធិទទួល Distance Education (សិក្សាពីចម្ងាយដោយមិនបាច់ទៅសាលារៀន)ឬទេ?**

ដើម្បីទទួលព័ត៌មានអំពី Distance Education (សិទ្ធិទទួល, មុខវិជ្ជាដែលផ្តល់, ការចុះឈ្មោះជាដើម) សូមបើកមើល www.distance.vic.edu.au

**តើអ្វីទៅដែលខ្ញុំត្រូវរួមបញ្ចូលនៅក្នុងកម្មវិធី VCE របស់ខ្ញុំ?**

សាលារៀនអ្នកនឹងផ្តល់ឱវាទដើម្បីធានាថា អ្នកនឹងរើសយក unit តាមចំនួនត្រឹមត្រូវ និងការគួបផ្សំ unit ដ៏ត្រឹមត្រូវ ដើម្បីប្រឡងយក VCE របស់អ្នក។ អ្នកនឹងមានឱកាសដើម្បីយល់ព្រមការចុះឈ្មោះរបស់អ្នក និងឆែកមើលសិទ្ធិទទួលរបស់អ្នកនៅលើក្រដាសបំពេញព័ត៌មានផ្ទាល់ខ្លួន នៅដើមឆ្នាំ។

ដើម្បីទទួល VCE របស់អ្នក អ្នកត្រូវបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ unit យ៉ាងតិចចំនួន 16 ។

ដោយមិនគិតនូវចំនួន unit ដែលអ្នកសិក្សារួមគ្នាទាំងអស់នោះ អ្នកត្រូវបំពេញសព្វគ្រប់គួរជាទីពេញចិត្ត:

- unit ចំនួន 3 យ៉ាងតិច ចេញពីក្រុមអង់គ្លេសដូចតទៅនេះ:
  – Foundation English (អង់គ្លេសមូលដ្ឋាន) unit ទី 1 និងទី 2
  – អង់គ្លេស / អង់គ្លេសជាភាសាទីពីរ (ESL) unit ទី 1 – ទី 4
  – ភាសាអង់គ្លេស unit ទី 1 – ទី 4
  – អក្សរសាស្ត្រ unit ទី 1 – ទី 4

គេមិនរាប់ unit ទី 1 និងទី 2 ច្រើនជាងពីរ unit ទៅក្នុងតម្រូវការអង់គ្លេសឡើយ។ ដើម្បីទទួលពិន្ទុ ENTER មួយ អ្នកត្រូវបំពេញសព្វគ្រប់ទាំង unit ទី 3 និងទី 4 នៃលំដាប់អង់គ្លេសមួយ។

- បណ្តាមុខវិជ្ជា unit ទី 3 និងទី 4 ចំនួនបីលំដាប់ បន្ថែមទៅនឹងលំដាប់ដែលរើសយកចេញពីក្រុមអង់គ្លេស។ លំដាប់ទាំងនេះអាចយកចេញពីបណ្តាមុខវិជ្ជា VCE និង / ឬ បណ្តាកម្មវិធី VET ។ អ្នកត្រូវដឹងថា VTAC ដាក់ការរឹតត្បិតលើការគួបផ្សំមួយចំនួននៃមុខវិជ្ជា VCE និង VET ។ បើអ្នកមានបំណងដាក់ពាក្យសុំយកឋានៈស្មើនឹងការចូលឧត្តមសិក្សាជាតិ (Equivalent National Tertiary Entrance Rank [ENTER]) នៅចំណាច់ VCE របស់អ្នក អ្នកនឹងត្រូវដឹងអំពីការរឹតត្បិតទាំងនេះ។ សូមពិភាក្សាជាមួយអ្នកសំរបសំរួល VCE របស់អ្នក។

## អំពី VET

មានជំរើសបីសំរាប់រាប់បញ្ចូល VET ជាផ្នែកនៃ VCE របស់អ្នក ហើយជំរើសទាំងនេះត្រូវបានពណ៌នាដូចខាងក្រោមនេះ។

## 1. តើកម្មវិធី VCE VET គឺជាអ្វីទៅ?

អ្នកអាចជ្រើសយកកម្មវិធី VCE VET មួយជាផ្នែកនៃ VCE របស់អ្នក។ កម្មវិធី VCE VET ផ្តល់ឲ្យអ្នកនូវវិញ្ញាបនបត្រវិជ្ជាជីវៈមួយដោយមានឥណទាន VCE នៅក្នុងនោះ ដូចគ្នានឹងមុខវិជ្ជាឯទៀតរបស់ VCE ដែរ។ កម្មវិធី VCE VET នឹងផ្តល់ឲ្យអ្នកនូវឥណទានសំរាប់ unit ទី 1-ទី 4 ។ នេះមានន័យថា អ្នកនឹងត្រូវធ្វើការបណ្តុះបណ្តាលនៅក្នុងផ្នែកវិជ្ជាជីវៈជាក់លាក់មួយ ឧទាហរណ៍: បដិសណ្ឋារកិច្ច (hospitality), កសិកម្ម, បច្ចេកវិទ្យាព័ត៌មាន ឬវិស្វកម្ម។

ជាផ្នែកនៃការបណ្តុះបណ្តាលរបស់អ្នក អ្នកនឹងបំពេញការរៀនសូត្រនៅកន្លែងធ្វើការដែលមានការរៀបចំ ហើយដែលផ្តល់ឲ្យអ្នកនូវឱកាសដើម្បីហាត់អនុវត្តផ្ទាល់នូវតិរិវិជ្ជានិងជំនាញរបស់អ្នក។

ការបណ្តុះបណ្តាលនេះនឹងរួមចំណែកចំពោះការបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ VCE របស់អ្នក ហើយវានឹងផ្តល់ឲ្យអ្នកនូវលក្ខណៈសម្បត្តិវិជ្ជាជីវៈដែលទទួលស្គាល់ទូទាំងប្រទេស។ លក្ខណៈសម្បត្តិវិជ្ជាជីវៈនេះនឹងផ្តល់ឲ្យអ្នកនូវលទ្ធភាពទទួលការបណ្តុះបណ្តាលបន្ថែមទៀត ឧទាហរណ៍: នៅវិជ្ជាស្ថាន TAFE មួយ ហើយអាចកែលំអឱកាសអ្នកក្នុងការមានការងារធ្វើ នៅពេលដែលអ្នកចាកចេញពីសាលារៀន។

កម្មវិធីមួយចំនួនក៏មានពិន្ទុមុខវិជ្ជាមួយដែរ ហើយកម្មវិធីទាំងនេះនិងកម្មវិធី VCE VET ភាគច្រើនឯទៀត រួមចំណែកចំពោះ ENTER ។ គ្រាសព្វថ្ងៃនេះ គេមានកម្មវិធី VCE VET ជាង 30 សំរាប់ឲ្យសិស្សជ្រើសរើស។

កូនសៀវភៅកម្មវិធីសំរាប់កម្មវិធីនីមួយៗនៃកម្មវិធី VCE VET មាននៅតាមវ៉ិបសៃ VCAA គឺ www.vcaa.vic.edu.au សាលារៀនអ្នកមានកូនសៀវភៅកម្មវិធីទាំងនេះផងដែរ។

អ្នកអាចសាកសួរអ្នកសំរបសំរួល VCE ឬ VET របស់សាលាអ្នក ដើម្បីស្វែងដឹងនូវរបៀបដែលកម្មវិធី VCE VET នីមួយៗនឹងរួមចំណែកចំពោះ VCE របស់អ្នក។

## 2. តើការហាត់ធ្វើកូនជាងថ្មីនៅតាមសាលារៀន ឬការបណ្តុះបណ្តាលធ្វើការ គឺជាអ្វីទៅ?

វិធីមួយទៀតសំរាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីរួមចំណែកចំពោះ VCE របស់អ្នក គឺតាមរយៈការហាត់ធ្វើកូនជាងថ្មីនៅតាមសាលារៀន (School Based New Apprenticeship [SBNA]) ឬការបណ្តុះបណ្តាលធ្វើការ។ ដើម្បីធ្វើជាអ្នកហាត់រៀនធ្វើកូនជាង ឬអ្នកទទួលការបណ្តុះបណ្តាលធ្វើការ អ្នកត្រូវធ្វើការដែលទទួលបៀវត្សរ៍ និងចុះហត្ថលេខាលើកិច្ចសន្យាបណ្តុះបណ្តាល ដែលត្រូវចុះឈ្មោះជាមួយនឹងការិយាល័យបណ្តុះបណ្តាលនិងការអប់រំឧត្តមសិក្សា (Office of Training and Tertiary Education [OTTE])។

កម្មវិធី VCE របស់អ្នកនឹងប្រើពេលរួមគ្នាជាមួយនឹងការងារមិនពេញពេល និងការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អ្នក។ ដូច្នេះ VCE របស់អ្នកនឹងមានបីផ្នែក:

- មុខវិជ្ជា VCE ដែលសិក្សានៅឯសាលារៀន
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាធ្វើទៅនៅវិជ្ជាស្ថាន TAFE
- ការងារមិនពេញពេលដែលទទួលបៀវត្សរ៍ នៅក្នុងឧស្សាហកម្មមួយដែលអ្នកកំពុងធ្វើការបណ្តុះបណ្តាល។

គ្រាសព្វថ្ងៃនេះ មានឧស្សាហកម្មចំនួនដប់មួយដែល VCAA បានរៀបចំឲ្យមានឡើងនៅក្នុងការរៀបចំឥណទាន VCE ហើយអ្នកអាចសិក្សាធ្វើកូនជាងឬបណ្តុះបណ្តាលធ្វើការ ជាផ្នែកនៃ VCE របស់អ្នក។

លក្ខណៈសម្បត្តិ SBNA ដែលអ្នកទទួល នឹងរួមចំណែកចំពោះការបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ VCE នៅក្នុងវិធីដូចគ្នាដែលកម្មវិធី VCE VET រួមចំណែកដែរ គឺថា វានឹងផ្តល់ឲ្យអ្នកនូវឥណទានសំរាប់ unit ទី 1 - ទី 4 ។ កម្មវិធី SBNA រួមចំណែកចំពោះ ENTER តាមលក្ខណៈដូចគ្នាដែលកម្មវិធី VCE VET រួមចំណែកដែរ។

អ្នកនឹងត្រូវតែសាកសួរសាលារៀនអ្នកដើម្បីស្វែងដឹងនូវរបៀបដែលអាចបង្កើត SBNA មួយសំរាប់អ្នក។

កម្មវិធី VCE VET និង SBNA ក៏អាចបង្កើតផ្នែកនៃកម្មវិធីរៀនសូត្រ VCAL របស់សិស្សផងដែរ។ គេពន្យល់អំពី VCAL នៅផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

**3. ការទទួលស្គាល់ប្លុកឥណទាននៅក្នុង VCE**

បើអ្នកចាប់អារម្មណ៍ក្នុងការសិក្សាយកវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈដែលពុំមាននៅតាមរយៈកម្មវិធី VCE VET ឬ SBNA ចំនួនឯប់មួយដែលនិយាយខាងលើនេះ អ្នកក៏អាចរាប់បញ្ចូលការបណ្តុះបណ្តាលនេះឆ្ពោះទៅកាន់ការបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ VCE របស់អ្នកផងដែរ។

គេហៅការរៀបចំឥណទាននេះថា “ប្លុកឥណទាន (Block Credit)”។ មានបទបញ្ញត្តិខ្លះអំពីរបៀបដែលគេផ្តល់ឥណទាននៅក្នុង VCE តាមរយៈវិធីនេះ។ អ្នកគួរពិភាក្សាជាមួយអ្នកសំរបសំរួល VET ឬ VCE របស់អ្នក ដើម្បីទទួលព័ត៌មានបន្ថែម។

## តើខ្ញុំប្រឡងជាប់ VCE តាមរបៀបណា?

ផ្នែកបន្ទាប់នេះពណ៌នានូវរបៀបដែលអ្នកត្រូវសិក្សាដើម្បីប្រឡងជាប់ VCE ។ ផ្នែកនេះក៏ពណ៌នានូវកិច្ចការដែលអ្នកនឹងត្រូវធ្វើ របៀបដែលគេនឹងរាយការណ៍ប្រាប់អ្នកនូវពិន្ទុនៃកិច្ចការអ្នក និងការប្រើប្រាស់ផ្សេងៗដែលលទ្ធផលទាំងនេះអាចផ្តល់ឲ្យអ្នក។

### តើខ្ញុំត្រូវធ្វើអ្វីដើម្បីឲ្យប្រឡងជាប់?

ការប្រឡងជាប់ VCE មានន័យថា ជោគជ័យរបស់អ្នកនឹងនៅជាប់នឹងខ្លួនអ្នកតាមទំរង់ជាវិញ្ញាបនបត្រដែលត្រូវបានទទួលស្គាល់ទូទាំងប្រទេសអូស្រ្តាលី និងអន្តរជាតិ។ ការប្រឡងជាប់តម្រូវថា:

- អ្នកបានបំពេញគួរជាទីពេញចិត្តនូវតម្រូវការនៃកម្មវិធី VCE ។
- កិច្ចការរបស់អ្នកបានទទួលការឲ្យពិន្ទុ និងបានរកឃើញថា ទទួលស្តង់ដារគួរជាទីពេញចិត្ត។

### តើខ្ញុំនឹងដឹងអំពីស្តង់ដារតាមរបៀបណា?

នៅពេលដែលអ្នកជ្រើសយកកម្មវិធីមួយដែលនឹងអនុញ្ញាតឲ្យអ្នកបំពេញតាមតម្រូវការប្រឡងជាប់ហើយ អ្នកត្រូវធ្វើកិច្ចការដែលល្អគ្រប់គ្រាន់ដើម្បីឲ្យអ្នកប្រឡងជាប់។ ការប្រឡងជាប់ VCE គឺអាស្រ័យលើការបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវបណ្តា unit ដែលបង្កើតជាមុខវិជ្ជានីមួយៗរបស់អ្នក។ ការបំពេញសព្វគ្រប់គួរជាទីពេញចិត្តត្រូវបានបង្ហាញឲ្យឃើញឡើងតាមរយៈលទ្ធផល ‘S’។ ការមិនធ្វើបានតាមតម្រូវការសំរាប់ការបំពេញសព្វគ្រប់គួរជាទីពេញចិត្តត្រូវបានបង្ហាញតាមរយៈលទ្ធផល ‘N’។

សាលាអ្នកជាអ្នកធ្វើសេចក្តីសំរេចចិត្តអំពីការបំពេញសព្វគ្រប់គួរជាទីពេញចិត្ត ថាតើអ្នកបំពេញសព្វគ្រប់នូវ unit ទី 1 និងទី 2 ឬ unit ទី 3 និងទី 4 ។

សេចក្តីសំរេចចិត្តអំពីការបំពេញសព្វគ្រប់គួរជាទីពេញចិត្ត ត្រូវបានផ្អែកលើការបង្ហាញរបស់អ្នកនូវលទ្ធផលនៃកំប្លេនីមួយៗ នៅក្នុងការរៀបចំសិក្សាសំរាប់មុខវិជ្ជានីមួយៗ។ លទ្ធផលនីមួយៗពណ៌នានូវអ្វីៗដែលគេរំពឹងឲ្យអ្នកដឹង និងអាចធ្វើ (តំរិះវិជ្ជានិងជំនាញសំខាន់)នៅនឹងពេលដែលអ្នកបានបំពេញ unit នីមួយៗ។ unit នីមួយៗនៃមុខវិជ្ជា VCE មានលទ្ធផលចាប់ពីពីរដល់បួន។

សំរាប់មុខវិជ្ជាទាំងអស់ សាលារៀនអ្នកសំរេចថា តើអ្នកបានបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ unit ណាមួយឬទេ។ ដើម្បីធ្វើសេចក្តីសំរេចចិត្តនេះ សាលារៀនអ្នកនឹងកំណត់កិច្ចការត្រូវដាក់ពិន្ទុ ដើម្បីឲ្យដឹងថា តើអ្នកកំពុងរីកចំរើនយ៉ាងណាដែរ។ កិច្ចការទាំងនេះនឹងកំណត់ដោយគ្រូបង្រៀនអ្នក ចេញពីបញ្ជីមួយនៅក្នុងការរៀបចំការសិក្សា ហើយឲ្យពិន្ទុនៅក្នុងរង្វង់សាលារៀន។ គ្រូបង្រៀនអ្នកនឹងផ្តល់ឲ្យអ្នកនូវបញ្ជីមួយនៃកិច្ចការទាំងឡាយ និងថ្ងៃកំណត់ចុងក្រោយសំរាប់ប្រគល់កិច្ចការទាំងនេះមកវិញ។ អ្នកនឹងត្រូវផ្តល់មូលហេតុល្អណាស់ដើម្បីពន្យារពេលនៃថ្ងៃកំណត់ចុងក្រោយ ដូច្នេះបើអ្នកមានថ្ងៃកំណត់ចុងក្រោយច្រើនជាងមួយក្នុងរង្វង់ពេលដ៏ខ្លី អ្នកនឹងត្រូវគ្រោងធ្វើកិច្ចការទាំងអស់ឲ្យហើយកុំឲ្យហួសថ្ងៃកំណត់ចុងក្រោយនោះ។ ការមិនធ្វើតាមថ្ងៃកំណត់ចុងក្រោយរបស់សាលារៀនអ្នកអាចមានន័យថា មិនបានបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ unit នោះ។

ចំពោះ unit ទី 1 និងទី 2 ជាទូទៅ សាលារៀនផ្តោតលើលទ្ធផល ‘S’ ឬ ‘N’ (យ៉ាងណាមិញ សាលារៀនខ្លះអាចរាយការណ៍អំពីថាតើអ្នកបានទទួលលទ្ធផលល្អយ៉ាងណាដែរ នៅក្នុងកិច្ចការត្រូវដាក់ពិន្ទុ ដោយផ្តល់កំរិតពិន្ទុលើកិច្ចការរបស់អ្នក)។

### តើគេនឹងដាក់ពិន្ទុឲ្យខ្ញុំរបៀបណាសំរាប់ unit ទី 3 និងទី 4?

ចំពោះ unit ទី 3 និងទី 4 អ្នកនឹងទទួលក៏រិតពិន្ទុ ព្រមទាំង ‘S’ ឬ ‘N’ ដូចដែលបានពណ៌នានៅខាងលើ។ VCAA ជាអ្នកមើលខុសត្រូវការដាក់ពិន្ទុរបស់សិស្សទាំងអស នៅនឹងក៏រិត unit ទី 3 និងទី 4 ។

កិច្ចការត្រូវដាក់ក៏រិតពិន្ទុ គឺជាកិច្ចការធ្វើនៅសាលារៀន ឬការប្រឡង។ មុខវិជ្ជា VCE នីមួយៗមានកិច្ចការត្រូវដាក់ក៏រិតពិន្ទុចំនួនបីសំរាប់លំដាប់ unit ទី 3 និងទី 4 ដោយមានកិច្ចការធ្វើនៅសាលាពីរនិងការប្រឡងមួយ ឬ កិច្ចការធ្វើនៅសាលាមួយនិងការប្រឡងពីរ។ ដំណើរការស្រដៀងគ្នានៃកិច្ចការត្រូវដាក់ពិន្ទុ អនុវត្តចំពោះកម្មវិធី VCE VET ដែលជ្រើសយកដាក់ពិន្ទុ ហើយដែលមានកិច្ចការធ្វើនៅសាលាមួយនិងការប្រឡងមួយ។ គ្រប់មុខវិជ្ជា VCE មានការប្រឡងយ៉ាងតិចក៏មួយដែរ។

កិច្ចការធ្វើនៅសាលាមានពីរប្រភេទនៅក្នុង VCE ។

គេហៅប្រភេទទីមួយថា កិច្ចការសិក្សាឲ្យពិន្ទុដោយសាលារៀន (School-assessed Coursework)។ ប្រភេទនៃកិច្ចការសិក្សានេះពិនិត្យវាយតម្លៃថាតើអ្នកបានធ្វើកិច្ចការត្រូវដាក់ពិន្ទុបានល្អយ៉ាងណាដែរ។ កិច្ចការទាំងនេះត្រូវធ្វើជាចំបងនៅក្នុងពេលម៉ោងនៅតាមថ្នាក់រៀន។ មុខវិជ្ជាទាំងអស់ លើកលែងតែសិល្បៈស្ទូឌីយោ (Studio Arts) ចេញ ត្រូវរួមបញ្ចូលនៅក្នុងកិច្ចការសិក្សាឲ្យពិន្ទុដោយសាលារៀន។

ប្រភេទទីពីរនៃកិច្ចការនៅសាលារៀន គឺកិច្ចការឲ្យពិន្ទុដោយសាលារៀន (School-assessed Task)។ មុខវិជ្ជាតែប្រាំពីរប៉ុណ្ណោះដែលមានកិច្ចការឲ្យពិន្ទុដោយសាលារៀន: សិល្បៈ, តាក់តែងរៀបចំនិងបច្ចេកវិជ្ជា, អាហារនិងបច្ចេកវិជ្ជា, ប្រព័ន្ធព័ត៌មាន, សិល្បៈស្ទូឌីយោ, វិស្វកម្មប្រព័ន្ធ, ហើយនិងចក្ខុប្រាស្រ័យទាក់ទងនិងការតាក់តែងរៀបចំ។ តម្រូវការសំរាប់កិច្ចការឲ្យពិន្ទុដោយសាលារៀនគឺដូចគ្នាសំរាប់សាលារៀនទាំងអស់ ហើយកំណត់ដោយ VCAA ។ សាលារៀនអ្នកនឹងរៀបចំសកម្មភាពនានាក្នុងរង្វង់តម្រូវការនានា ដើម្បីជួយអ្នកក្នុងការបំពេញកិច្ចការឲ្យពិន្ទុដោយសាលារៀននេះ។ VCAA បញ្ជាក់នូវពិន្ទុនិងចំណាត់ថ្នាក់ពិន្ទុដែលត្រូវផ្ដល់ទៅឲ្យសិស្ស។ គ្រូបង្រៀនរបស់អ្នកជាអ្នកឲ្យពិន្ទុ ហើយសាលារៀនអ្នកនឹងបញ្ជូនទៅឲ្យ VCAA នូវពិន្ទុមួយដើម្បីបង្ហាញថា តើអ្នកបានធ្វើល្អយ៉ាងណាដែរនូវកិច្ចការឲ្យពិន្ទុដោយសាលារៀន។

### ការប្រឡងនៅខាងក្រៅ

ការប្រឡងនៅខាងក្រៅ (សរសេរ, ផ្ទាល់មាត់, សំដែង ឬ អេឡិកត្រូនិក) ត្រូវបានកំណត់និងឲ្យពិន្ទុដោយ VCAA ។ ការប្រឡងភាគច្រើនគឺធ្វើនៅខែវិច្ឆិកា ប៉ុន្តែមុខវិជ្ជាមួយចំនួនតូចធ្វើការប្រឡងនៅខែមិថុនា ឬ តុលា។

### តើអ្វីទៅដែលជាការឆែកពិនិត្យកិច្ចការឲ្យពិន្ទុរបស់ VCE?

សំរាប់រាល់ទំរង់ទាំងអស់នៃកិច្ចការត្រូវដាក់ពិន្ទុ ទាំងកិច្ចការឲ្យពិន្ទុនៅសាលារៀននិងការប្រឡង VCAA មានទំរង់ការដ៏ម៉ត់ចត់ដើម្បីធានាថា សាលារៀនទាំងអស់នៅពាសពេញរដ្ឋឲ្យពិន្ទុសិស្សតាមស្តង់ដារដូចគ្នា។ ទំរង់ការទាំងនោះជាប់ទាក់ទងនឹងទំរង់ការស្ថិតិ និងការឆែកពិនិត្យយ៉ាងច្រើនទៅលើចំណុចនីមួយៗនៃកិច្ចការត្រូវដាក់ពិន្ទុរបស់អ្នក។ អ្នកអាចទទួលព័ត៌មានលំអិតពីសាលារៀនអ្នក ឬវិបសៃរបស់ VCAA ។

## តើ GAT គឺជាអ្វីទៅ?

តេស្តលទ្ធផលទូទៅ (General Achievement Test [GAT]) គឺជាតេស្តគឺវិជ្ជានិងជំនាញនៅក្នុងការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ, គណិតសាស្ត្រ, វិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា, មនុស្សជាតិ, សិល្បៈនិងវិទ្យាសាស្ត្រសង្គម។

GAT គឺជាផ្នែកសំខាន់មួយនៃទំរង់ការឲ្យពិន្ទុរបស់ VCE ។ ទោះជាវាមិនមែនជាផ្នែកនៃតម្រូវការប្រឡងជាប់ និងមិនរាប់បញ្ចូលក្នុងលទ្ធផលនៃ VCE ឬ ENTER របស់អ្នកក្តី ក៏ GAT មានតួនាទីសំខាន់ក្នុងការឆែកពិនិត្យថា តើគេបានដាក់ពិន្ទុត្រឹមត្រូវឬទេចំពោះកិច្ចការឲ្យពិន្ទុនៅសាលារៀនអ្នក និងការប្រឡងទាំងឡាយ។

ហេតុនេះ បើអ្នកចុះឈ្មោះរៀន unit ទី 3 និងទី 4 នៃមុខវិជ្ជាណាមួយរបស់ VCE ឬកម្មវិធីឲ្យពិន្ទុណាមួយនៃ VCE VET – ទោះជានៅក្នុងថ្នាក់ទី 11 ឬទី 12 – អ្នកត្រូវធ្វើតេស្ត GAT លើកលែងតែអ្នកមានការលើកលែងដោយ VCAA ។ ត្រូវមាន

មូលហេតុល្អសំរាប់ការលើកលែងនេះ។
គេនឹងរាយការណ៍នូវលទ្ធផល GAT របស់អ្នក ជាមួយនឹងរបាយការណ៍នៃលទ្ធផល (Statement of Results) របស់អ្នក។

## តើគេនឹងរាយការណ៍មកឲ្យខ្ញុំតាមវិធីណានូវលទ្ធផលរបស់ខ្ញុំ?

### របាយការណ៍នៃលទ្ធផល

បើអ្នករៀន unit ទី 1 និងទី 2 តែប៉ុណ្ណោះ អ្នកនឹងទទួលរបាយការណ៍នៃលទ្ធផលតាមរយៈសាលារៀនអ្នក។ បើអ្នករៀន unit ទី 3 និងទី 4 VCAA នឹងផ្ញើរបាយការណ៍នៃលទ្ធផលទៅឲ្យអ្នកនៅខែធ្នូ។

របាយការណ៍នៃលទ្ធផលនឹងបង្ហាញថា តើអ្នកបានទទួលលទ្ធផល 'S' ឬ 'N' ឬទេ សំរាប់ unit ទាំងអស់ដែលអ្នកចុះឈ្មោះរៀន – unit ទី 1, ទី 2, ទី 3 និងទី 4។

ការឲ្យពិន្ទុរបស់អ្នកសំរាប់កិច្ចការសិក្សាឲ្យពិន្ទុដោយសាលារៀន (School-assessed Coursework), កិច្ចការឲ្យពិន្ទុដោយសាលារៀន (School-assessed Tasks) និងការប្រឡង នឹងត្រូវរាយការណ៍ជាកំរិតពិន្ទុចាប់ពី A+ ដល់ E ឬ UG (មិនដាក់ពិន្ទុ)។

បើអ្នកទទួលកិច្ចការត្រូវដាក់ពិន្ទុចាប់ពីពីរឡើងទៅ និងទទួលលទ្ធផល 'S' សំរាប់ទាំង unit ទី 3 និងទាំងទី 4 នៅក្នុងមុខវិជ្ជាមួយ អ្នកនឹងទទួលពិន្ទុមុខវិជ្ជាមួយ។ ពិន្ទុមុខវិជ្ជាត្រូវបានគណនាលើកំរិត 0-50 ហើយជារង្វាស់រង្វាល់ថាតើអ្នកបានធ្វើកិច្ចការល្អយ៉ាងណាដែរ បើប្រៀបធៀបនឹងអ្នកឯទៀតទាំងអស់ដែលបានសិក្សាមុខវិជ្ជានេះ។ ពិន្ទុមុខវិជ្ជាដែលគណនាដោយ VCAA នឹងត្រូវប្រើដោយមណ្ឌលទទួលចូលឧត្តមសិក្សារដ្ឋវិកតូរីយ៉ា (Victorian Tertiary Admissions Centre [VTAC]) ដើម្បីគណនា ENTER របស់អ្នក (សូមអាន"កិច្ចការផ្សេងទៀតដែលខ្ញុំប្រហែលជាចង់ដឹង"នៅខាងក្រោម)។

បើអ្នកបានបំពេញសព្វគ្រប់នូវ unit ទាំងឡាយរបស់ VCE VET ពិន្ទុទាំងនេះនឹងត្រូវបង្ហាញនៅក្នុងរបាយការណ៍នៃលទ្ធផលរបស់អ្នក ហើយបើអ្នកបានបំពេញកម្មវិធី VCE VET ពេញលេញមួយ អ្នកនឹងទទួលវិញ្ញាបនបត្រដោយឡែកមួយពីអង្គការបណ្ដុះបណ្ដាលចុះបញ្ជី (Registered Training Organisation [RTO]) បន្ថែមទៅនឹង VCE របស់អ្នក។ បើអ្នកបានធ្វើកិច្ចការត្រូវដាក់ពិន្ទុសំរាប់ពិន្ទុមុខវិជ្ជានៅក្នុងកម្មវិធី VCE VET មួយ ពិន្ទុរបស់អ្នកនឹងត្រូវរាប់បញ្ចូលទៅក្នុងរបាយការណ៍នៃលទ្ធផល ព្រមជាមួយនឹងមុខវិជ្ជាទាំងឡាយនៃ VCE ។

### វិញ្ញាបនបត្រ **VCE**

អ្នកក៏នឹងទទួលវិញ្ញាបនបត្រមួយផងដែរបើអ្នកបានបំពេញគួរជាទីពេញចិត្តនូវតម្រូវការសំរាប់ការប្រឡងជាប់ VCE ។

## កិច្ចការផ្សេងទៀតដែលខ្ញុំប្រហែលជាចង់ដឹង

### មុខវិជ្ជាពង្រីក

មុខវិជ្ជាពង្រីកគឺជាមុខវិជ្ជាសាកលវិទ្យាល័យដែលសិក្សាជាមួយនឹង VCE ។ បើអ្នកជាសិស្សពូកែខ្លាំង ហើយចង់បានការខិតខំប្រឹងប្រែងបន្ថែម មុខវិជ្ជាទាំងនេះគឺជាវិធីល្អមួយដើម្បីពង្រីកចំណាប់អារម្មណ៍របស់អ្នកនៅក្នុងមុខវិជ្ជាមួយដែលស្ថិតនៅហួសពី VCE មួយជំហាន។ មុខវិជ្ជាទាំងនេះមិនមែនជា unit នៃ VCE ទេ ហើយមិនអាចរាប់បញ្ចូលជាផ្នែកនៃ unit ចំនួន 16 ដែលចាំបាច់សំរាប់បំពេញសព្វគ្រប់គួរជាទីពេញចិត្តនោះឡើយ។

### អ្នកណាទៅដែលអាចសិក្សាមុខវិជ្ជាពង្រីក?

មុខវិជ្ជាពង្រីកគឺសំរាប់សិស្សពូកែខ្លាំង ដែលបានទទួលលទ្ធផលល្អក្រៃលែង។ ជារៀងរាល់ឆ្នាំ សិស្ស VCE ប្រហែល 2 ភាគ

រយនឹងមានសិទ្ធិសិក្សា។ សិស្សដាក់ពាក្យសុំដោយផ្ទាល់ទៅកាន់សាកលវិទ្យាល័យដែលផ្តល់មុខវិជ្ជាតាមជំរើសរបស់ខ្លួន។ សិស្សគួរស្វែងរកឱវាទពីសាលាខ្លួន មុនពេលចាប់ផ្តើមសិក្សាមុខវិជ្ជាពង្រីកមួយ។ សលារៀនអ្នកនឹងមានគោលការណ៍ណែនាំដែលកំណត់ដោយសាកលវិទ្យាល័យ ដែលជួយធានាថា សិស្សដែលជ្រើសសំរាំងទាំងឡាយមានសមត្ថភាពសិក្សា VCE របស់ខ្លួន និងកម្មវិធីមុខវិជ្ជាពង្រីក។ កម្មវិធីមុខវិជ្ជាពង្រីកទាំងអស់ យ៉ាងតិចក៏មានចំនួន 20 ភាគរយដែរនៃកម្មវិធីពេញពេលឆ្នាំដំបូងនៅសាកលវិទ្យាល័យ។

ចំណុចសំខាន់មួយនៃការជ្រើសយកគឺការសំរេចបានរបស់អ្នកនៅក្នុងមុខវិជ្ជារៀបចំ VCE សំរាប់កម្មវិធីមុខវិជ្ជាពង្រីកដែលអ្នកចង់សិក្សា។ មុខវិជ្ជារៀបចំនេះនឹងផ្តល់ឲ្យអ្នកនូវទំរង់ដើមចាំបាច់សំរាប់មុខវិជ្ជាសាកលវិទ្យាល័យ នៅក្នុងកម្មវិធីមុខវិជ្ជាពង្រីករបស់អ្នក។ ជាធម្មតា អ្នកនឹងត្រូវបំពេញសព្វគ្រប់នូវលំដាប់ unit ទី 3 និងទី 4 មួយ នៅក្នុងមុខវិជ្ជារៀបចំមួយ ដែលផ្តល់ឲ្យអ្នកនូវទំរង់ដើមចាំបាច់សំរាប់មុខវិជ្ជាសាកលវិទ្យាល័យ។ អ្នកអាចសិក្សាមុខវិជ្ជារៀបចំខ្លះនៅគ្រាជាមួយគ្នានឹងមុខវិជ្ជាពង្រីក។ អ្នកគួរស្វែងរកឱវាទលើបញ្ហានេះពីសាលារៀននិងសាកលវិទ្យាល័យ។ សាលារៀនអ្នកក៏នឹងត្រូវពេញចិត្តថា អ្នកបានលទ្ធផល ឬ នឹងទទួលលទ្ធផលពិន្ទុមុខវិជ្ជា VCE មួយ យ៉ាងតិចក៏ 41 ដែរនៅក្នុងមុខវិជ្ជារៀបចំ (ដើម្បីទទួលព័ត៌មានអំពីពិន្ទុមុខវិជ្ជាទាំងឡាយ សូមអាន"តើគេនឹងរាយការណ៍មកឲ្យខ្ញុំតាមវិធីណានូវលទ្ធផលរបស់ខ្ញុំ")។

## តើមានផលប្រយោជន៍អ្វីខ្លះទៅ?

បើអ្នកបំពេញដោយជោគជ័យនូវមុខវិជ្ជាពង្រីក លទ្ធផលទាំងឡាយនឹងត្រូវរាយការណ៍នៅក្នុងរបាយការណ៍នៃលទ្ធផល ហើយអាចរួមចំណែកដល់ ENTER របស់អ្នក (អាន"របាយការណ៍នៃលទ្ធផល") ជាមុខវិជ្ជា VCE ទីប្រាំមួយ។ វាអាចធ្វើឲ្យអ្នកទទួលពិន្ទុ 4.0, 5.0 ឬ 5.5 ទៅនឹងចំនួនផ្តុំសរុបនៅក្នុងការគណនា ENTER របស់អ្នក ដោយអាស្រ័យលើលទ្ធផលរបស់អ្នកនៅក្នុងមុខវិជ្ជាពង្រីក។ បើអ្នកប្រឡងជាប់កម្មវិធីមុខវិជ្ជាពង្រីក ជាធម្មតាអ្នកនឹងអាចសិក្សាមុខវិជ្ជានោះនៅឆ្នាំទីពីរនៅសាកលវិទ្យាល័យ បើអ្នកត្រូវបានជ្រើសរើសចូលរៀនវគ្គសិក្សាដែលមានមុខវិជ្ជានោះ។

អ្នកត្រូវចងចាំថា ការចុះឈ្មោះរៀនមុខវិជ្ជាពង្រីកមានន័យថា អ្នកនឹងមានបន្ទុកកិច្ចការកាន់តែធំ ព្រមទាំងកិច្ចការនៃថ្នាក់កាន់តែខ្ពស់ឡើង ប៉ុន្តែក៏ទទួលបានរង្វាន់ក៏មានភាពធំធេងផងដែរ។

បើអ្នកគិតថា កម្មវិធីនេះគឺសំរាប់អ្នក សូមធ្វើការទាក់ទងជាដំបូងជាមួយនឹងសាកលវិទ្យាល័យដើម្បីស្វែងដឹងព័ត៌មានថែមទៀតនៃមុខវិជ្ជាពង្រីកដែលគេផ្តល់ឲ្យ។ មុខវិជ្ជាទាំងឡាយដែលផ្តល់ឲ្យដោយសាកលវិទ្យាល័យនីមួយៗ និងវិធីដែលមាន អាចផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ហើយជាការសំខាន់ដែលអ្នកត្រូវដឹងអំពីបញ្ហានេះ បើនិងនៅពេលដែលអ្នកធ្វើសេចក្តីសំរេចចិត្តចុះឈ្មោះក្នុងកម្មវិធីមុខវិជ្ជាពង្រីកនោះ។

## តើខ្ញុំអាចចូលសិក្សានៅសាកលវិទ្យាល័យ ឬ TAFE តាមរបៀបណា?

VCAA គណនាពិន្ទុមុខវិជ្ជាអ្នក ចេញពីកិច្ចការត្រូវដាក់ពិន្ទុចំនួនបី ក្នុងមុខវិជ្ជានីមួយៗ។ ពិន្ទុសរុបសំរាប់មុខវិជ្ជានីមួយៗគឺ 50 ។ ដោយប្រើពិន្ទុមុខវិជ្ជាសំរាប់ unit ទី 3 និងទី 4 ដែលគណនាដោយ VCAA, VTAC កំណត់ ENTER របស់អ្នក។ មុខវិជ្ជាឯទៀតដែលប្រើនៅក្នុងការគណនា ENTER របស់អ្នក អាចមានរួមទាំងកម្មវិធី VCE VET និងមុខវិជ្ជាពង្រីកទាំងពួង។ ENTER ត្រូវបានប្រើជាប្រភពចំបងនៃការជ្រើសរើសនៅក្នុងវគ្គសិក្សាជិត 50 ភាគរយ។ សំរាប់វគ្គសិក្សាសេសសល់ឯទៀត អាជ្ញាធរជ្រើសរើសប្រើលក្ខណៈវិនិច្ឆ័យផ្សេងៗដែលអាចមានរួមទាំង ENTER និងការឡើងបកស្រាយកិច្ចការសរសេរ (folio), សំដែងសំរាប់ជ្រើសរើស (auditions), បទសំភាសន៍ជាដើម។ គេបង្កើត ENTER ឡើងដោយប្រៀបធៀបជាមួយនឹងសិស្សទាំងឡាយនៅតាមមុខវិជ្ជាទាំងអស់របស់សិស្ស ហើយជាប់ទាក់ទងនឹងការធ្វើស្ថិតិនៃពិន្ទុមុខវិជ្ជាដោយកែប្រែពិន្ទុទាំងនោះ ឲ្យទៅជាពិន្ទុសំរាប់ ENTER ។ នេះមានន័យថា មុខវិជ្ជាទាំងអស់ត្រូវបានគេគិតគូរឲ្យបានស្មើគ្នាដោយអនុញ្ញាតឲ្យបូកបញ្ចូលទាំងអស់នេះដើម្បីទទួលបានចំនួនផ្តុំសរុបមួយ ដែលបន្ទាប់មកត្រូវបានកែប្រែទៅជា ENTER មួយ។ ឯកសារបោះពុម្ព VTAC តទៅនេះ មានព័ត៌មានបន្ថែមទៀតអំពីដំណើរការនេះ និងការជ្រើសរើសចូលឧត្តមសិក្សា:

*Enter into Tertiary Study (ការចូលទៅកាន់ការសិក្សានៅឧត្តមសិក្សា)* (រ៉ុបសៃ VTAC តែប៉ុណ្ណោះ)

*ABC of Scaling (ABC នៃការធ្វើកម្រិត)* (ផ្ញើមួយច្បាប់ទៅជាមួយនឹងរបាយការណ៍ ENTER នៅខែធ្នូ)

*Choice! (ជំរើស!)* (កូនសៀវភៅថ្នាក់ទី 10 មាននៅតាមសាលារៀន)

*VTAC Guide 2007 (គោលការណ៍ណែនាំ VTAC ឆ្នាំ 2007)* (មាននៅតាមហាងលក់សៀវភៅនិងទស្សនាវដ្ដី)

Victorian Tertiary Entrance Requirements (VICTER) (តម្រូវការចូលទៅកាន់ឧត្តមសិក្សារដ្ឋវិកតូរីយ៉ា) 2008 ឬ 2009 (កូនសៀវភៅថ្នាក់ទី 10 មាននៅតាមសាលារៀន)

វ៉ិបសៃ VTAC: www.vtac.edu.au

## ការទទួលស្គាល់ការសំរេចបាននៅក្នុង VCE

មានវិធីជាច្រើននៅក្នុង VCE សំរាប់ឲ្យសិស្សបង្ហាញនូវកិច្ចខិតខំនិងកោសល្យរបស់ខ្លួន។ ការរួមចំណែករបស់សិស្សចំពោះសាលារៀននិងសហគមន៍របស់ខ្លួន ត្រូវបានគេទទួលស្គាល់តាមរយៈ VCE Achievers Award (រង្វាន់អ្នកសំរេចបាន VCE)។ ឧត្តមភាពនៃកិច្ចការដែលសិស្សធ្វើបាននៅឆ្នាំនីមួយៗ ត្រូវបានគេទទួលស្គាល់តាមរយៈ VCE Season of Excellence (រដូវឧត្តមភាព VCE) ដែលមានរួមទាំង Top Designs (ការតុបតែងរៀបចំកំពូល), Top Class (ថ្នាក់កំពូល), Top Screen (ភាពយន្តកំពូល), Top Acts (ការសំដែងកំពូល) និង Top Arts (សិល្បៈកំពូល)។ គេក៏មាន Premier’s Awards (រង្វាន់របស់អភិបាលរដ្ឋ), VCAA Plain English Speaking Award (រង្វាន់និយាយអង់គ្លេសសាមញ្ញ VCAA), និង Australian Students Prize (រង្វាន់សិស្សអូស្ត្រាលី)ផងដែរ។

ដើម្បីទទួលព័ត៌មានបន្ថែមអំពីរង្វាន់ទាំងនេះ សូមបើកមើលវ៉ិបសៃ VCAA នៅឯ:

www.vcaa.vic.edu.au/excellenceawards/seasonofexcellence/index.html
www.vcaa.vic.edu.au/excellenceawards/vceachiever.html
www.vcaa.vic.edu.au/excellenceawards/australianstudentprize.html
www.vcaa.vic.edu.au/excellenceawards/premiersaward.html
www.vcaa.vic.edu.au/excellenceawards/plainenglishspeaking/index.html

## អំពី VCAL

ដើម្បីទទួលព័ត៌មានអំពី VCAL សូមបើកមើលវ៉ិបសៃ VCAA និងចុចនៅត្រង់
www.vcaa.vic.edu.au/vce/publications/WhereToNow/vcallote.html